**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# គោលការណ៍ឯកភាពរួមរវាង

## មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និងកាមរោគ

## និង

## មជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និង ហង់សិន

ដើម្បីកាត់បន្ថយនូវអត្រាឈឺនិងស្លាប់ក្នុងចំណោមអ្នកជំងឺរបេងនិងអ្នកផ្ទុកមេរោគអេដស៍ ក្រសួងសុខាភិបាលបានឯកភាពអោយបង្កើតក្រុមការងារជំនាញរបេង-អេដស (TB-HIV Technical Working Group) នៅឆ្នាំ២០០០ និងបង្កើតគណៈកម្មការសំរបសំរួលសកម្មភាពថែទាំព្យាបាលអ្នកជំងឺរបេងអេដស៍នៅឆ្នាំ២០០៥។ មជ្ឈមណ្ឌលជាតិទាំងពីរបានសហការជាមួយដៃគូអភិវឌ្ឍន៍ បកប្រែនិងរៀបចំឯកសារ ស្តីពីការថែទាំនិងព្យាបាលជំងឺអេដស៍និងជំងឺរបេងនៅឆ្នាំ២០០១ និងគំរោងប្រយុទ្ធនឹងជំងឺរបេង-អេដស៍ នៅកម្ពុជានៅឆ្នាំ ២០០៣ ដែលបច្ចុប្បន្នកំពុងតែធ្វើការកែសំរួលឡើងវិញ ។

ទន្ទឹមនឹងនេះ មជ្ឈមណ្ឌលជាតិទាំងពីរបានឯកភាពជាគោលការណ៍លើតួនាទី និងភារកិច្ចរបស់មជ្ឈមណ្ឌលនីមួយៗក្នុងការជំរុញការអនុវត្តន៍គំរោងប្រយុទ្ធនឹងជំងឺរបេង-អេដស៍នៅកម្ពុជា ដែលមានចែងក្នុងគោលការណ៍ឯកភាពរួមចុះថ្ងៃទី ០១ ខែ មិនា ឆ្នាំ២០០៥ និងបានរៀបចំនិយាមស្តីពីបែបបទនៃការអនុវត្តន៍អំពីការធ្វើតេស្តសំរាប់ធ្វើរោគវិនិច្ឆ័យជំងឺរបេង-អេដស៍អោយបានទាន់ពេលវេលាដើម្បីទទួលសេវាថែទាំព្យាបាលបានរហ័ស ដែលបានទទួលការអនុម័តពីក្រសួងសុខាភិបាលនៅថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៦។

ដើម្បីកាត់បន្ថយអត្រាឆ្លង អត្រាឈឺ និងអត្រាស្លាប់ដោយសារជំងឺរបេងចំពោះអ្នកផ្ទុកមេរោគអេដស៍ អោយនៅទាបបំផុតនោះ (ឈានទៅលប់បំបាត់នៅឆ្នាំ២០២០) ក្រសួងសុខាភិបាលបានឯកភាពលើនិយាមនៃបែបបទសំរាប់អនុវត្តការបង្កើនការពិនិត្យសុខភាពរករោគសញ្ញាជំងឺរបេង, ការព្យាបាលបង្ការជំងឺរបេងដោយប្រើឱសថ Isoniazid និងការបង្ការការចំលងមេរោគរបេង (យុទ្ធសាស្រ្ត Three I's) នៅតាមបណ្តាសេវាថែទាំនិងព្យាបាលបន្តសំរាប់អ្នកផ្ទុកមេរោគអេដស៍និអ្នកជំងឺអេដស៍ ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១០។

ដើម្បីជំរុញការអនុវត្តន៍នូវនិយាមនៃបែបបទខាងលើនេះ (SOP for implementing 3Is) មជ្ឈមណ្ឌលជាតិទាំងពីរបានឯកភាពលើភារកិច្ចទទួលខុសត្រូវដូចមានចែងខាងក្រោមនេះ:

**១. មជ្ឈមណ្ឌលជាតិកំចាត់ជំងឺរបេងនិងហង់សិន (CENAT) ទទួលខុសត្រូវក្នុងការ :**

- ធ្វើរោគវិនិច្ឆ័យជំងឺរបេងចំពោះអ្នកផ្ទុកមេរោគអេដស៍ដែលបញ្ជូនមកពីសេវា OI និង ART និង សេវាថែទាំព្យាបាលជំងឺអេដស៍លើកុមារ (Pediatric AIDS Care) នៅសេវាព្យាបាលជំងឺរបេង នៃមន្ទីរពេទ្យបង្អែក ។
- ផ្តល់ឱសថ INH ( 100 mg) និង វីតាមីន B6 (25 mg) តាមការស្នើសុំរបស់សេវា OI និង ART ( មនុស្សចាស់ និង កុមារ) និងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ។
- ផ្តល់សំភារៈត្រួតពិនិត្យការចំលងរោគមួយចំនួន ពិសេសម៉ាស់រាប់ ម៉ាស់ ធម្មតា និងម៉ាស់ពិសេស(N95)

  ពិនិត្យសុខភាពរកជំងឺរបេងរាប់បញ្ចូលទាំងការថតសួត (X-Ray) ជាទៀងទាត់ (រៀងរាល់ឆ្នាំ) ក្នុងចំណោមមន្ត្រី សុខាភិបាលដែលធ្វើការងារនៅសេវា CoC (សេវា OI និង ART មាន : គ្រូពេទ្យ, អ្នកផ្តល់ប្រឹក្សា, អ្នកស្ម័គ្រចិត្ត PLHIV) ជាដើម ។
- ធ្វើតេស្ត TST ចំពោះអ្នកផ្ទុកមេរោគអេដស៍មុនពេលចាប់ផ្តើម IPT ប្រសិនបើអាចធ្វើបាន ។
- សហការចូលរួម ក្នុងការបណ្តុះបណ្តាលបុគ្គលិកសុខាភិបាល ដែលពាក់ពន្ធ័ នឹងការងារ 3I នេះ ។

**២. មជ្ឈមណ្ឌលជាតិប្រយុទ្ធជាតិនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ (NCHADS) ទទួលខុសត្រូវ:**

- ជួយពិនិត្យសុខភាពរករោគសញ្ញាជំងឺរបេងក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍ (TB Symptom Screening Based)
- បញ្ជូនអ្នកសង្ស័យឆ្លងមេរោគរបេងទៅសេវាព្យាបាលជំងឺរបេង (TB Service) ដើម្បីធ្វើរោគវិនិច្ឆ័យជំងឺរបេង ។
- ផ្តល់ការឧបត្ថម្ភបច្ចេកទេស (រៀបចំផែនការ សិក្ខាសាលាតំរង់ទិស) និងសំភារៈដល់សេវា OI និង ART អោយដំណើរការ ICF និង IPT ព្រមទាំង TB Infection Control ដោយភាពរលូននិងប្រកបដោយគុណភាពខ្ពស់ព្រមទាំងការតាមដានផង (Monitoring and Evaluation)។
- ផ្សព្វផ្សាយអំពីលទ្ធផលការងារនេះប្រចាំត្រីមាសជូនដល់គ្រប់ភាគីពាក់ព័ន្ធនិងអ្នកត្រូវការទាំងអស់ ជាពិសេសតាមរយៈ Website របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និង មជ្ឈមណ្ឌលជាតិកំចាត់រោគរបេងនិងហង់សិន ។

ភ្នំពេញ ថ្ងៃទី..១៤....ខែ មិថុនា...ឆ្នាំ ២០១០

**ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ**

វេជ្ជ. មាន_ឈីវុន

**ប្រធានមជ្ឈមណ្ឌលជាតិកំចាត់រោគរបេងនិងហង់សិន**

វេជ្ជ. ម៉ៅ_តាន់អ៊ាង

**ចំលងជូនៈ**

- ខុទ្ទកាល័យក្រសួងសុខាភិបាល
- អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
- នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង
- នាយកដ្ឋានមន្ទីរពេទ្យ
- មន្ទីរសុខាភិបាលខេត្ត/រាជធានីពាក់ព័ន្ធ
- កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត/រាជធានីពាក់ព័ន្ធ
- ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិពាក់ព័ន្ធ
- មន្ទីរពេទ្យបង្អែកពាក់ព័ន្ធ
- មណ្ឌលសុខភាពពាក់ព័ន្ធ
- អង្គការសុខភាពពិភពលោក (WHO)
- អង្គការ UNICEF
- អង្គការ UNFPA
- អង្គការ UNAIDS
- អង្គការ FHI
- មូលនិធិគ្លីន (CHAI)
- អង្គការ KHANA
- US-CDC/GAP
- អង្គការ USAID

"ដើម្បីជូនជ្រាបជាព័តិមាន"

- ប្រធានក្រុម OI និង ART (មនុស្សចាស់ និង កុមារ)
- ប្រធានមណ្ឌលសុខភាពពាក់ព័ន្ធពាក់ព័ន្ធ
- ប្រធានសេវាសំរាលកូនពាក់ព័ន្ធ

"ដើម្បីអនុវត្ត"

- ឯកសារ